Australian Aid

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# គម្រោងបញ្ចប់ អំពើហិង្សា លើស្ត្រី នៅកម្ពុជា (EVAW)

របាយការណ៍វឌ្ឍនភាពលើកទី២

ខែកញ្ញា ឆ្នាំ២០១៦





ប្រធានគ្រប់គ្រងករណីគម្រោង Hagar រាជធានីភ្នំពេញជួបជាមួយនឹងក្រុមគ្រួសារជនរងគ្រោះ

ព័ត៌មាន និងទិន្នន័យទាំងនេះត្រូវបានផ្តល់ដោយដៃគូអនុវត្តគម្រោង EVAW តាមរយៈរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ២០១៦។

ទិន្នន័យដែលទទួលបានពីអង្គការ GIZ ត្រូវបានបែងចែកដើម្បីឆ្លុះបញ្ចាំងអំពីសមាមាត្រនៃមូលនិធិដែលគាំទ្រដោយក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលីហៅកាត់ថា (DFAT) និងមូលនិធិដែលគាំទ្រដោយ BMZ។

ឈ្មោះរបស់បុគ្គលក្នុងករណីសិក្សាត្រូវបានផ្លាស់ប្តូរដើម្បីការពារអត្តសញ្ញាណរបស់ពួកគាត់។

រូបថតនៅក្នុងឯកសារនេះត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយដៃគូអនុវត្តគម្រោង។

# មាតិកា


គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី ........ ២

ដៃគូគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី ........ ៤

វិសាលភាពនៃសកម្មភាពគម្រោង ........ ៥

បច្ចុប្បន្នភាពលទ្ធផលនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ សេវាកម្ម ការបង្ការ និងយុត្តិធម៌ ........ ៦

បច្ចុប្បន្នភាពលទ្ធផលនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការពង្រឹងស្ថាប័ន ........ ៨

បច្ចុប្បន្នភាពលទ្ធផលនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការសិក្សាស្រាវជ្រាវ និងភស្តុតាង ........ ១១

ករណីសិក្សា ........ ១២



Services provided by Coffey International Development on behalf of DFAT.

# គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី

ការបញ្ចប់អំពើហិង្សាលើស្ត្រីគឺជាគន្លឹះក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងធ្វើឱ្យស្ត្រីមានសិទ្ធិពេញលេញក្នុងការចូលរួមក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមនៅកម្ពុជា។

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា គឺជាគម្រោងដែលមានភាពជាដៃគូរយៈពេលប្រាំឆ្នាំរវាងក្រសួងកិច្ចការនារី និង ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT) ចាប់ផ្តើមក្នុងឆ្នាំ២០១២។ ក្នុងគោលបំណងដើម្បីផ្លាស់ប្តូរឥរិយាបថ និងទប់ស្កាត់អំពើហិង្សាលើស្ត្រី ដូច្នេះស្ត្រី និងក្មេងស្រី អាចមានអារម្មណ៍សុវត្ថិភាពនៅក្នុងលំនៅដ្ឋាន និងសហគមន៍របស់ពួកគេ។

មិនមែនមានមូលហេតុតែមួយទេដែលបណ្តាលឱ្យមានអំពើហិង្សាលើស្ត្រី។ ទម្រង់ផ្សេងគ្នានៃអំពើហិង្សាត្រូវបានជំរុញដោយកត្តាជាច្រើនដូច្នេះចាំបាច់យើងត្រូវដោះស្រាយតាមរយៈការអន្តរាគមន៍ខុសៗគ្នា។ គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី បានផ្តោតលើការឆ្លើយតបក្នុងគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការរំលោភផ្លូវភេទ ការទទួលបានឱកាសរៀនពីរបៀបបង្ការ ការឆ្លើយតប ការសិក្សាស្រាវជ្រាវ និងភស្តុតាង។

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី គាំទ្រដល់ក្រសួងកិច្ចការនារីក្នុងការដឹកនាំ និងសម្របសម្រួលការឆ្លើយតបជាពហុវិស័យដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី និងពិចារណាលើគោលនយោបាយសំខាន់ពីររបស់ក្រសួងកិច្ចការនារី និងគោលនយោបាយរបស់រដ្ឋាភិបាលអូស្ត្រាលី។

### *ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤-២០១៨*

ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់ អំពើហិង្សាលើស្ត្រីលើកទីពីរគឺជាគោលនយោបាយចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់យុទ្ធសាស្ត្រសំខាន់ៗសម្រាប់រដ្ឋាភិបាល ស្ថាប័នជាតិ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិដើម្បីធ្វើការរួមគ្នាក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាលើស្ត្រី និងផ្តល់ការការពារដល់ជនរងគ្រោះដោយអំពើហិង្សា។

### *ផែនការយុទ្ធសាស្ត្រស្តីពីសមភាពយេនឌ័រ និងការលើកកម្ពស់ស្ត្រី - នារីរតនៈទី៤ ឆ្នាំ២០១៤-២០១៨*

ផែនការនារីរតនៈ លើកទី៤ គឺជាផែនការយុទ្ធសាស្ត្រប្រាំឆ្នាំសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅកម្ពុជា។ មានគោលបំណងដើម្បីគាំទ្រដល់ដំណើរការកំណែទម្រង់នៃក្រសួងកិច្ចការនារីក្នុងការផ្តល់ការវិភាគយេនឌ័រ ដ៏មានប្រសិទ្ធភាពការតស៊ូមតិ និងការផ្តល់អនុសាសន៍គោលនយោបាយដល់រាជរដ្ឋាភិបាល។



> *“អំពើហិង្សាដែលទាក់ទងនឹងយេនឌ័រគឺជាការបង្ហាញពីការរើសអើង និងបិទសិទ្ធិរបស់ស្ត្រី និងក្មេងស្រី។ យើងត្រូវតែជួយសម្រួលដល់ស្ត្រីក្នុងការទទួលបាននូវប្រព័ន្ធយុត្តិធម៌ និងសេវាចិត្តសង្គមដទៃទៀត និងឱ្យជនល្មើសទទួលខុសត្រូវលើទង្វើ និងបទឧក្រិដ្ឋដែលគេបានប្រព្រឹត្ត។”*

លោកជំទាវ វេជ្ជ. អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឆ្នាំ២០១៣

*យុទ្ធសាស្ត្រសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីរបស់រដ្ឋាភិបាលអូស្ត្រាលី (ខែកុម្ភៈ ឆ្នាំ២០១៦)*

សកម្មភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីនឹងគាំទ្រដល់វិស័យអាទិភាពទាំងបីនៃយុទ្ធសាស្ត្រសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីរបស់ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT) ដើម្បីដឹកនាំការងារសមភាពយេនឌ័រ។

១ លើកកម្ពស់សំឡេងស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការដឹកនាំ ការកសាងសន្តិភាព គាំទ្រតាមរយៈការលើកទឹកចិត្ត និងជំរុញឱ្យមានតំណាង និងអ្នកដឹកនាំជាស្ត្រីក្នុងការអនុវត្តកម្មវិធី។

**២៦** មេឃុំ/ចៅសង្កាត់ ជំទប់ឃុំ/សង្កាត់ និងសមាជិកគណៈកម្មាធិការឃុំ/សង្កាត់គាំទ្រ និងចូលរួមក្នុងការអនុវត្តន៍ប្រព័ន្ធសេចក្តីជូនដំណឹងអំពីបញ្ហាគ្រឿងស្រវឹងនៅតាមឃុំ/សង្កាត់ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាក្នុងសហគមន៍

**៤២** គណៈកម្មាធិការគ្រប់គ្រងដែលមានស្ត្រីជាតំណាង និងអ្នកចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត

២ លើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី៖ គាំទ្រតាមរយៈចំណូលគ្រួសារ យន្តការទប់ស្កាត់អំពើហិង្សា។

បន្ថែមពីការផ្តល់ប្រឹក្សា និងការផ្សព្វផ្សាយពីចំណេះដឹងអំពីសិទ្ធិស្ត្រី អង្គការបន្ទាយស្រីបានជួយលក្ខិណាក្នុងការដាំបន្លែ និងចិញ្ចឹមមាន់សម្រាប់គ្រួសារ។ បុគ្គលិកតែងតែតាមដានជាទៀងទាត់ក្នុងការផ្តល់ប្រឹក្សាក្នុងគ្រួសារ និងសេដ្ឋកិច្ច។ ឥឡូវការរកស៊ីដាំបន្លែរបស់លក្ខិណាមានដំណើរការល្អ ហើយមានផ្ទះសមរម្យមួយ និងម៉ូតូពីរគ្រឿង។ គេក៏បានពង្រីកមុខរបរចិញ្ចឹមជ្រូកសម្រាប់បង្កើនចំណូលគ្រួសារបន្ថែម។

> *“ពេលដែលគ្រួសារខ្ញុំរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ យើងគ្មានអ្វីទាំងអស់។ ឥឡូវខុសគ្នាឆ្ងាយពីមុន ព្រោះយើងលែងឈ្លោះគ្នាទៀតហើយ វាធ្វើឱ្យជីវភាពរបស់ពួកយើងប្រសើរឡើង។ ពីមុនខ្ញុំអស់សង្ឃឹមហើយមានបំណងចង់សម្លាប់ខ្លួន ប៉ុន្តែឥឡូវប្តីខ្ញុំ និងខ្ញុំមានក្តីសង្ឃឹមសម្រាប់អនាគត ខ្ញុំរីករាយខ្លាំងណាស់។”*

ករណីសិក្សា អង្គការបន្ទាយស្រី
ខេត្តបាត់ដំបង។

៣ បញ្ចប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី៖ គាំទ្រតាមរយៈការអនុវត្តន៍ជាមួយដៃគូនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី និងសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា។

គោលបំណងនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីគឺដើម្បីចូលរួមចំណែកក្នុងការឆ្លើយតបដ៏មានប្រសិទ្ធភាព ជាប្រព័ន្ធ និងគណនេយ្យភាព ការបង្ការអំពើហិង្សាលើស្ត្រីនៅកម្ពុជា។ ដើម្បីសម្រេចបានចំណុចទាំងនេះ គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានផ្តោតលើគោលដៅបី៖

**សេវាកម្ម៖** ដើម្បីធានាឱ្យបានការទទួលបានសេវាដែលមានគុណភាព និងសមរម្យសម្រាប់ជនរងគ្រោះដោយអំពើហិង្សា។

**ការបង្ការ៖** លើកកម្ពស់ការផ្លាស់ប្តូរជាវិជ្ជមានក្នុងសហគមន៍ ឥរិយាបថ អាកប្បកិរិយា ជំនឿក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី។

**យុត្តិធម៌៖** គាំទ្រដល់វិស័យច្បាប់ និងយុត្តិធម៌ក្នុងការឆ្លើយតបសម្រាប់ជនរងគ្រោះដោយអំពើហិង្សា និងចាប់ជនល្មើសឱ្យទទួលខុសត្រូវ។

មានគោលដៅពីរផ្សេងទៀតសម្រាប់គាំទ្រគោលដៅខាងលើ៖

**ការគាំទ្រស្ថាប័ន និងការសម្របសម្រួល៖** ធ្វើការជាមួយរដ្ឋាភិបាល វិស័យឯកជន អង្គការសង្គមស៊ីវិល ដើម្បីកែលម្អការគាំទ្រ និងសម្របសម្រួលក្នុងការឆ្លើយតបសម្រាប់ជនរងគ្រោះដោយអំពើហិង្សា។

**ការសិក្សាស្រាវជ្រាវ និងភស្តុតាង៖** ធ្វើការសិក្សាស្រាវជ្រាវ និងរកភស្តុតាងសម្រាប់ប្រើប្រាស់ក្នុងការកែលម្អផែនការ ការផ្តល់សេវា និងការអនុវត្តសេវាគាំទ្រ។

# ដៃគូគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានកំណត់ភាពខ្លាំង ចំណេះដឹង និងជំនាញរបស់ដៃគូ។ គម្រោងបានចាប់ផ្តើមក្នុងឆ្នាំ២០១២ ហើយមានដៃគូចំនួនបី។ ក្នុងឆ្នាំ ២០១៦- ២០១៧ ដៃគូអនុវត្តគម្រោងមានចំនួនដប់ប្រាំ រួមទាំងអង្គការជាតិ និងអន្តរជាតិដើម្បីផ្តល់សេវាកម្មវិធី។ រួមជាមួយក្រសួងកិច្ចការនារី និង DFAT ដៃគូអនុវត្តគម្រោងទាំងអស់ សរុបមានចំនួនដប់ប្រាំពីរ ដែលចូលរួមចំណែកក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា។

| ភ្នាក់ងារជាដៃគូ | លទ្ធផលបឋម | ពណ៌នាកម្មវិធី |
|---|---|---|
| ទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបច្ចេកទេស (ACTED) | ការបង្ការ | កាត់បន្ថយហានិភ័យនៃអំពើហិង្សាផ្លូវភេទ និងយេនឌ័រទៅលើបុគ្គលិកបម្រើសេវាកំសាន្តក្នុងទីក្រុងភ្នំពេញ។ ACTED សហការជាមួយអង្គការសេវាសង្គមនៅកម្ពុជា និងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ។ |
| អង្គការ Hagar | សេវាកម្ម | ផ្តល់ជំនួយ និងការគ្រប់គ្រងករណីក្នុងការជួយជនរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្សឱ្យសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ដែលមានសុវត្ថិភាព។ |
| ជំនួយផ្នែកច្បាប់នៅកម្ពុជា (LAC) | យុត្តិធម៌ | លើកកម្ពស់សិទ្ធិជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទតាមរយៈការពង្រឹងយន្តការច្បាប់ និងយុត្តិធម៌ដែលមានស្រាប់នៅថ្នាក់ក្រោមជាតិ។ |
| អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) | សេវាកម្ម | កែលម្អលទ្ធផលទទួលបានសេវាផ្នែកចិត្តសាស្ត្រសម្រាប់ជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ |
| អង្គការ CARE | សេវាកម្ម | ចូលរួមជាមួយអ្នកផ្តល់សេវាផ្នែកសុខភាព អាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍ដើម្បីបង្កើនការយល់ដឹង និងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រីក្នុងសហគមន៍របស់ពួកគេ។ |
| កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) | សេវាកម្ម | បង្កើនលទ្ធភាព និងគុណភាពនៃសេវាកម្មសម្រាប់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។ GIZ សហការជាមួយជំនួយផ្នែកច្បាប់នៅកម្ពុជា អង្គការចិត្តសង្គមអន្តរវប្បធម៌ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) និងអង្គការបន្ទាយស្រី (BS)។ |
| United Nations Entity for Gender Equity and the Empowerment of Women (UN Women) | ការគាំទ្រស្ថាប័ន និងការសម្របសម្រួល | គាំទ្រដល់ក្រសួងកិច្ចការនារីដើម្បីជំរុញការអនុវត្តន៍ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទីពីរ ២០១៤- ២០១៨ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ |
| អង្គការមូលនិធិអាស៊ី (TAF) | ការបង្ការ ស្រាវជ្រាវ និងភស្តុតាង | ចូលរួមចំណែកការពារអំពើហិង្សាលើដៃគូស្និទស្នាលដោយផ្តោតលើចំណុចសំខាន់ពីរគឺការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង និងការកាត់បន្ថយសារអវិជ្ជមានដែលនាំឱ្យមានអំពើហិង្សាលើស្ត្រី។ អង្គការមូលនិធិអាស៊ីសហការជាមួយ អង្គការចិត្តសង្គមអន្តរវប្បធម៌ វិទ្យាស្ថានបើកទូលាយ អង្គការពន្លឺកុមារកម្ពុជា មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព។ |
| មូលនិធិអង្គការសហប្រជាជាតិសម្រាប់សុខភាពប្រជាជន (UNFPA) | សេវាកម្ម | គាំទ្រដល់ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្របណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់វិស័យសុខាភិបាលក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី។ |
| មូលនិធិអង្គការសហប្រជាជាតិសម្រាប់សុខភាពប្រជាជន (UNFPA) | ការស្រាវជ្រាវ | ដើម្បីអនុវត្តការវិភាគលើកទីពីរនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០១៤ ការអង្កេតនិន្នាការនៃអំពើហិង្សា។ |

| ដៃគូអនុវត្ត | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| | ៣ | ៩ | ១៣ | ១៦ | ១៧ | ១៧ |

# វិសាលភាពនៃសកម្មភាពគម្រោង

សេវាសម្រាប់ជនរងគ្រោះដោយអំពើហិង្សាមានស្រាប់នៅទូទាំងប្រទេស ប៉ុន្តែវាមិនមានជាប់លាប់ ឬអាចប្រើប្រាស់បានសម្រាប់ស្ត្រីទាំងអស់នោះទេ។

សេវាទាំងអស់នេះរួមទាំងសេវារដ្ឋ និងឯកជនដូចជាការគាំទ្រផ្នែកច្បាប់ ជម្រកស្នាក់នៅដែលមានសុវត្ថិភាព ការគាំទ្រផ្លូវចិត្ត សុខភាព និងវេជ្ជសាស្ត្រ និងបណ្តាញអ្នកគាំទ្រស្ម័គ្រចិត្ត។

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី ធ្វើការនៅបណ្តាខេត្ត ស្រុក និងឃុំមួយចំនួន។

មានការកើនឡើងក្នុងឆ្នាំ២០១៦-២០១៧ រួមមាន៖

- UNFPA ចំនួន៩ខេត្ត
- UN Women ចំនួន២ខេត្ត
- CARE ចំនួន១៩សង្កាត់ក្នុងរាជធានីភ្នំពេញ
- TAF ពង្រីកចំនួន១១ឃុំបន្ថែមទៀត

| | ស្រុក | ឃុំ |
|---|---|---|
| CARE | ៤ | ១៩ |
| TAF | ៤ | ៣០ |
| GIZ | ២០ | ១៨១ |
| TPO | ១ | ៣ |
| LAC | ៦ | ៤៥ |
| ACTED | ៤ | ២៥ |




សកម្មភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី

Hagar មានគ្រប់ខេត្តទាំងអស់លើកលែងតែខេត្តមណ្ឌលគីរី

# បច្ចុប្បន្នភាពលទ្ធផលនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ សេវាកម្ម ការបង្ការ និងយុត្តិធម៌

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី បានផ្តល់ជំនួយលើការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ក្នុងជីវិតក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៤។ ការសិក្សានេះផ្តល់នូវទិន្នន័យប្រេវ៉ាឡង់ថ្នាក់ជាតិ និងផលវិបាកនៃអំពើហិង្សាលើស្ត្រី និងពង្រឹងតម្រូវការរបស់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។ ការសិក្សានេះបានរកឃើញថា៖

- ២១% នៃស្ត្រីដែលធ្លាប់មានដៃគូអាយុពី១៥ទៅ៦៤ឆ្នាំ រាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ និងផ្លូវភេទក្នុងមួយជីវិតរបស់ពួកគេ។
- ៨% រាយការណ៍ថាធ្លាប់ទទួលរងអំពើហិង្សាផ្លូវកាយ និងផ្លូវភេទក្នុងរយៈពេល១២ខែកន្លងមកនេះ។
- ៩០% រាយការណ៍ថាបានរងរបួសដោយដៃគូស្និទស្នាលរបស់ពួកគេវាយធ្វើបាប ហើយត្រូវការការថែទាំសុខភាព។
- មានតែ ២៤% ប៉ុណ្ណោះកំពុងស្វែងរកជំនួយផ្លូវការ។

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានស្វះស្វែងរកសេវាខុសៗគ្នា ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។

លទ្ធផលនៃសកម្មភាពដែលបានមកពីលទ្ធផលទាំងបី សេវាកម្ម ការបង្ការ និងយុត្តិធម៌ ត្រូវបានប្រមូលពីឆ្នាំ២០១៤-២០១៥ និង២០១៥-២០១៦ ពីរបាយការណ៍វឌ្ឍនភាពរបស់ដៃគូអនុវត្ត។

## ចំនួនអ្នកចូលរួមក្នុងសកម្មភាពគម្រោង EVAW




**៤០%**

មានការកើនឡើង៤០%នៃចំនួនអ្នកចូលរួមសរុប

**៥,៩៣០**

ក្នុងឆ្នាំ២០១៤-២០១៥ ទៅដល់

**៩,៩៥០**

ក្នុងឆ្នាំ២០១៥-២០១៦

ការផ្តល់ប្រឹក្សាជាសេវាសម្រាប់ជនរងគ្រោះដោយអំពើហិង្សា រួមមានការឆ្លើយតបទៅនឹងបញ្ហាសុខភាពផ្លូវចិត្ត គាំទ្រការផ្តល់ព័ត៌មាន និងបញ្ជូនសម្រាប់អ្នករងការបៀតបៀនផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងការរំលោភផ្លូវភេទ។

ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយនៅសហគមន៍ជាវេទិកា ឬព្រឹត្តការណ៍ដែលមានគោលបំណងឱ្យទទួលបានចំណេះដឹង អាកប្បកិរិយាឥរិយាបថក្នុងការឆ្លើយតប និងយល់ដឹងអំពីផលប៉ះពាល់នៃអំពើហិង្សាលើស្ត្រី។

ការអន្តរាគមន៍ផ្នែកច្បាប់ជាការរួមបញ្ចូលគ្នានូវសកម្មភាពកសាងសមត្ថភាពសម្រាប់អាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងប្រសើរជាងមុនលើកាតព្វកិច្ចរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងការផ្តល់សេវាផ្នែកច្បាប់សម្រាប់ជនរងគ្រោះដោយអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។

# ការពង្រឹងសមត្ថភាពសហគមន៍ក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីផ្តល់ការគាំទ្រទាំងផ្នែកភាពជាអ្នកដឹកនាំ និងគាំទ្រដល់សមាជិកសហគមន៍ក្នុងការលើកយកផលប៉ះពាល់នៃអំពើហិង្សាជាលក្ខណៈបុគ្គល គ្រួសារ និងសហគមន៍របស់ពួកគាត់។

ការផ្តល់វគ្គបណ្តុះបណ្តាល កម្មវិធីជួយខ្លួនឯង និងសកម្មភាពនៃការផ្សព្វផ្សាយបានបង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ។

*“ បច្ចុប្បន្ន ការរស់នៅក្នុងសហគមន៍មានភាពល្អប្រសើរជាងមុន។ ប្រជាពលរដ្ឋមិនមានការខ្លាចរអារដូចមុន និងមានការយល់ដឹងពីរបៀបដោះស្រាយបញ្ហានៅពេលដែលពួកគាត់ជួបប្រទះ។ ”*

ករណីសិក្សារបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ ក្នុងខេត្តបាត់ដំបង



ក្រុមជួយខ្លួនឯង កម្មវិធី TPO ក្នុងខេត្តបាត់ដំបង

**៧**

បណ្តាញកុមារតស៊ូមតិត្រូវបានបង្កើតឡើងក្នុងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាផ្ទាល់ខ្លួន និងសុវត្ថិភាពសហគមន៍

**៣០**

មេឃុំ/ចៅសង្កាត់បានគាំទ្រ និងដឹកនាំការអនុវត្តន៍ប្រព័ន្ធសេចក្តីជូនដំណឹងអំពីបញ្ហាគ្រឿងស្រវឹងនៅតាមឃុំសង្កាត់

**៥៩**

អតិថិជនដែលបានធ្វើសមាហរណកម្មទៅក្នុងគ្រួសារជាមួយនឹងការគាំទ្រពីមេឃុំ/ចៅសង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារឃុំ/សង្កាត់

**២២៩**

អតិថិជន និងគ្រួសាររបស់ពួកគាត់បានទទួលការប្រឹក្សាយោបល់ ការគ្រប់គ្រងករណី និងសេវាលើកកម្ពស់ផ្នែកសេដ្ឋកិច្ច

**៣៥**

ក្រុមជួយខ្លួនឯងត្រូវបានបង្កើតឡើងសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការរំលោភផ្លូវភេទ និងការសេពគ្រឿងស្រវឹង ដែលមានបញ្ហាផ្លូវចិត្ត និងបញ្ហាចិត្តសង្គម

**៨២**

ធនធានមនុស្សសហគមន៍ បានទទួលការបណ្តុះបណ្តាលលើការថែទាំសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្រ

**៤១៥**

មិត្តអប់រំមិត្តបានចូលរួមលើកកម្ពស់សុវត្ថិភាព និងសេរីភាពបុគ្គលអំពីអំពើហិង្សា ការបៀតបៀនផ្លូវភេទដល់ស្ត្រីបម្រើសេវាកំសាន្ត

# បច្ចុប្បន្នភាពលទ្ធផលនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖ ការពង្រឹងស្ថាប័ន

## គោលនយោបាយ និងការអនុវត្តគោលការណ៍ណែនាំ




គោលបំណងសំខាន់នៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី គឺការគាំទ្រដល់ក្រសួងកិច្ចការនារីក្នុងការដឹកនាំ និងសម្របសម្រួលការឆ្លើយតបពហុវិស័យដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី។

លទ្ធផលដែលទទួលបានគួរឱ្យកត់សម្គាល់គឺការបង្កើតឡើង និងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទីពីរ ២០១៤-២០១៨។

កិច្ចសហការ និងសម្របសម្រួលរវាងអ្នកផ្តល់សេវា និងភ្នាក់ងារអនុវត្តសំខាន់ៗបានចេញជាលទ្ធផលដូចជា ការបង្កើតការអនុវត្តគោលការណ៍មួយចំនួនក្នុងការគាំទ្រដល់ភ្នាក់ងារផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សា។ បណ្តុំនៃគោលការណ៍ណែនាំទាំងនោះរួមបញ្ចូលទាំងក្របខ័ណ្ឌច្បាប់នៃព្រះរាជាណាចក្រកម្ពុជាមួយចំនួនដែលមានស្រាប់។ និយមន័យ និងគោលការណ៍ណែនាំនីមួយៗមានភាពស្របគ្នាដើម្បីសម្របសម្រួលជាមួយភ្នាក់ងារផ្សេងទៀត និងអន្តរក្រសួងស្ថាប័នក្នុងការប្រើប្រាស់ប្រព័ន្ធបញ្ជូន និងការផ្តល់សេវា។

- **គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រី ដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ៖** លើកកម្ពស់ការទទួលបានសេវាតាមរយៈប្រព័ន្ធនៃការចុះបញ្ជីករណី ការសិក្សាពីតម្រូវការ និងការបញ្ជូនដោយផ្អែកតាមតម្រូវការបុគ្គល និងកិច្ចព្រមព្រៀងរបស់ជនរងគ្រោះ យើងទទួលស្គាល់ថា ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានតម្រូវការជាពហុវិស័យដែលមិនអាចឆ្លើយតបដោយការផ្តល់សេវាតែមួយប្រភេទនោះទេ។

- **ប្រព័ន្ធគ្រប់គ្រងទិន្នន័យ៖** ប្រព័ន្ធរបាយការណ៍សាមញ្ញមួយអំពីសេវាដែលបានផ្តល់ និងបញ្ជូនមានការយល់ដឹងពីតម្រូវការសេវា ភាពចន្លោះប្រហោងនៃការផ្តល់សេវា និងការរាំងស្ទះនៃការផ្តល់សេវាឱ្យមានភាពប្រសើរឡើង ។

- **បទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាយោបល់ជាមូលដ្ឋានដល់ស្ត្រីនិងកុមារជាជនរងគ្រោះដោយសារអំពើហិង្សាដែលទាក់ទងនឹងយេនឌ័រ៖** ជាការណែនាំដល់ភ្នាក់ងារផ្តល់សេវាទាំងអស់ ដើម្បីឱ្យប្រាកដថាកញ្ចប់គោលការណ៍នេះ ជួយសម្រួលដល់ភាពឯកជន ទំនុកចិត្ត និងគោរពសិទ្ធិជនរងគ្រោះនូវរាល់ព័ត៌មានទាំងឡាយណាដែលបានផ្តល់ និងការសម្រេចចិត្តលើអនាគតរបស់ពួកគាត់។

- **សៀវភៅគ្លីនិកសុខភាពសម្រាប់ស្ត្រីដែលរងគ្រោះដោយអំពើហិង្សា និងការរំលោភផ្លូវភេទលើដៃគូស្និទ្ធស្នាល៖** ជាការណែនាំសម្រាប់អ្នកផ្តល់សេវាសុខាភិបាលនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដើម្បីបង្កើនការយល់ដឹងបន្ថែមពីអំពើហិង្សាលើស្ត្រី និងការផ្តល់ការគាំទ្រដំបូង និងការគ្រប់គ្រងសម្រាប់ជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទជាស្ត្រី។



កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខេត្តបាត់ដំបង កម្មវិធីជំនួយផ្នែកច្បាប់នៅកម្ពុជា

# គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានជួយសម្របសម្រួលដល់អ្នកផ្តល់សេវា និងដៃគូអនុវត្ត

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីចាប់ផ្តើមធ្វើការជាមួយដៃគូចំនួន១ ដែលអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងខេត្តចំនួន២

បច្ចុប្បន្ន គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីមានដៃគូចំនួន៥ ដែលកំពុងអនុវត្តគោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងខេត្តគោលដៅចំនួន៩ និងរាជធានីភ្នំពេញ។




## បណ្តាញការងារសំខាន់ៗ

តួនាទីរបស់រាជរដ្ឋាភិបាលគឺបង្កើនការទទួលខុសត្រូវនៅថ្នាក់ក្រោមជាតិ។ តាមរយៈសកម្មភាពគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី ក្រសួង ស្ថាប័នរដ្ឋជាច្រើន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានការកើនឡើងចំណេះដឹង និងការអភិវឌ្ឍន៍សមត្ថភាពតាមរយៈការចូលរួមក្នុងបណ្តាញការងារ និងវេទិកានានាក្នុងគោលបំណងគាំទ្រ និងសម្របសម្រួលការឆ្លើយតបសម្រាប់ជនរងគ្រោះដោយអំពើហិង្សា។

| | |
|---|---|
| **ក្រុមការងារបច្ចេកទេសយេនឌ័រ-អំពើហិង្សាទាក់ទងនឹងយេនឌ័រ** | ▸ ១៥ ក្រសួង ស្ថាប័ន<br>▸ ១០ ដៃគូអភិវឌ្ឍ<br>▸ ៣០ សង្គមស៊ីវិលជាសមាជិក |
| **ក្រុមការងារអន្តរក្រសួង** | ▸ ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលបង្កើតបទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាយោបល់ជាមូលដ្ឋានដល់ស្ត្រី និងកុមារជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>▸ ក្រសួងកិច្ចការនារី ក្រសួងព័ត៌មាន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកំពុងតែពិចារណាលើរូបភាពអំពើហិង្សាលើស្ត្រីក្នុងកម្មវិធីទូរទស្សន៍ |
| **បណ្តាញអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងគណៈកម្មការនានា** | ▸ គាំទ្រគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ដើម្បីលើកកម្ពស់ការយល់ដឹងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងការដោះស្រាយវិវាទ<br>▸ គាំទ្រគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្នាក់ស្រុក និងគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារឃុំ/សង្កាត់ ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងកុមារ<br>▸ គាំទ្របណ្តាញយេនឌ័រថ្នាក់ខេត្តដែលជារចនាសម្ព័ន្ធមួយសម្រាប់ការផ្លាស់ប្តូរព័ត៌មាន ការរៀនសូត្រ ការសម្របសម្រួល និងការតាមដានករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>▸ គាំទ្របណ្តាញព្រហ្មទណ្ឌយុត្តិធម៌ក្នុងការលើកកម្ពស់និងគ្រប់គ្រងបញ្ហាផ្នែកច្បាប់សម្រាប់ស្ត្រីនិងកុមារប្រកបដោយប្រសិទ្ធភាព<br>▸ គាំទ្រក្រុមការងារទទួលបន្ទុកអំពើហិង្សាទាក់ទងនឹងយេនឌ័រដើម្បីលើកយកបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រដាក់ជូនភាគីពាក់ព័ន្ធសម្រាប់ដោះស្រាយជាមួយគ្នានៅកម្រិតថ្នាក់ខេត្ត |
| **ការកសាងសមត្ថភាពមន្ត្រីក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី** | ▸ ក្រុមបណ្តាញមន្ត្រីវ័យក្មេងក្រសួងកិច្ចការនារីមានសមាជិកសរុបចំនួន៨០រូប<br>▸ បានគាំទ្រដល់ភ្នាក់ងារនគរបាលយុត្តិធម៌ក្រសួងកិច្ចការនារីតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលនៅក្នុងខេត្តសៀមរាប និងកំពង់ធំ<br>▸ មន្ត្រីក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីខេត្តទទួលបានវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយ និងការអនុវត្តគោលការណ៍ណែនាំនានា |

# ការបណ្តុះបណ្តាល

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានគាំទ្រកម្មវិធីបណ្តុះបណ្តាលនៅតាមតំបន់គោលដៅមួយចំនួនអំពីយេនឌ័រនៅតាមស្ថាប័នដើម្បីឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី។ គោលបំណងនៃការបណ្តុះបណ្តាលនេះគឺដើម្បីបង្កើនចំណេះដឹង និងការយល់ដឹងរបស់អាជ្ញាធរមូលដ្ឋាន ភ្នាក់ងារផ្តល់សេវាសុខាភិបាល និងមន្ត្រីផ្នែកច្បាប់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសេវាសម្រាប់ជនរងគ្រោះដោយអំពើហិង្សា។

ទិន្នន័យខាងក្រោមត្រូវបានផ្តល់ដោយដៃគូអនុវត្តគម្រោងចាប់ពីខែមករា ដល់ខែសីហា ឆ្នាំ២០១៦។

## មន្ត្រីច្បាប់ និងមន្ត្រីយុត្តិធម៌




## ភ្នាក់ងារសុខាភិបាល




## អាជ្ញាធរមូលដ្ឋាន




## សរុបអ្នកចូលរួមវគ្គបណ្តុះបណ្តាល



# បច្ចុប្បន្នភាពលទ្ធផលនៃគម្រោងបញ្ចប់អំពើហិង្សាលើស្ត្រី៖
# ការសិក្សាស្រាវជ្រាវ និងឯកសារ

គម្រោងបញ្ចប់អំពើហិង្សាលើស្ត្រីបានគាំទ្រលើការសិក្សាស្រាវជ្រាវមួយចំនួនដើម្បីឱ្យមានការយល់ដឹងបន្ថែមទៀតលើបរិបទ និងនិន្នាការអំពើហិង្សាបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា និងផ្តល់ជាជម្រើសសម្រាប់ការប្រើប្រាស់ទិន្នន័យដើម្បីចូលរួមក្នុងគោលនយោបាយទប់ស្កាត់អំពើហិង្សា។

- ការប៉ាន់ប្រមាណពីតម្រូវការយេនឌ័រនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៤៖សេចក្តីសង្ខេបសម្រាប់គោលនយោបាយ ជំពូកទី៧ ស្តីពីអំពើហិង្សាលើស្ត្រី និងក្មេងស្រី http://bit.ly/mowaCGA2014en
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី១៖ ការប្រើប្រាស់បំពានគ្រឿងស្រវឹងនៅកម្ពុជា http://asiafoundation.org/publications/pdf/1584
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី២៖ ការមើលឃើញតាមប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា http://asiafoundation.org/publications/pdf/1585
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី៣៖ ការធ្លាប់ជួបប្រទះអំពើហិង្សាតាំងពីកុមារភាពនៅកម្ពុជា http://asiafoundation.org/publications/pdf/1586
- សេចក្តីសង្ខេបសម្រាប់កំណត់គោលដៅទី៤៖ ការទទួលបានការអប់រំនៅកម្ពុជា http://asiafoundation.org/publications/pdf/1587
- ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា (CDHS)៖ http://countryoffice.unfpa.org/cambodia/drive/2014CDHSKIR_2-20-2015.pdf
- ការសិក្សាស្រាវជ្រាវថ្នាក់ជាតិស្តីពីសុខភាពស្ត្រី និងបទពិសោធន៍ក្នុងជីវិតនៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៥៖ http://www.wpro.who.int/mediacentre/releases/2015/vaw_full-en.pdf
- បញ្ចប់អំពើហិង្សាលើស្ត្រីនៅកម្ពុជា៖ របាយការណ៍លើកទី១ស្តីពី បច្ចុប្បន្នភាពគម្រោង ឆ្នាំ២០១៥ http://dfat.gov.au/about-us/publications/Documents/cambodia-ending-violence-against-women-program-summary-achievements-2014-15.PDF
- ផែនការសកម្មភាពជាតិស្តីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី លើកទី២ ឆ្នាំ២០១៤-២០១៨ http://cambodia.unfpa.org/publications/national-action-plan-prevent-violence-against-women-2014-2018


























# ករណីសិក្សា

*“គោលការណ៍របស់សាលាបានអនុវត្តកម្មវិធីពិសេសមួយស្តីពីការប្រើប្រាស់គ្រឿងស្រវឹងទៅដល់សិស្សានុសិស្ស។ ខ្ញុំពិតជាឃើញពីការថយចុះរាល់ទម្រង់នៃអំពើហិង្សានៅក្នុងឃុំរបស់ខ្ញុំ។ យុវជនធ្លាប់តែសេពគ្រឿងស្រវឹង និងបង្កផលលំបាកជារឿយៗ ប៉ុន្តែឥឡូវនេះអ្នកមិនបានឃើញពួកគេប្រព្រឹត្តបែបនោះទៀតទេ៕”*

ក្រុមប្រឹក្សាឃុំ ក្នុងខេត្តស្វាយរៀង តំបន់អនុវត្តកម្មវិធីរបស់អង្គការមូលនិធិអាស៊ី

*“ឥឡូវនេះជនរងគ្រោះមានទំនុកចិត្ត។ ពួកគេដឹងថា នៅពេលដែលពួកគេជួបបញ្ហា មានអ្នកជួយពួកគេ។ លើសពីនេះទៅទៀត នីតិវិធីរបស់នគរបាលមានភាពប្រសើរជាងមុន មិនត្រឹមតែប៉ុណ្ណោះនីតិវិធីតុលា និងប្រព័ន្ធយុត្តិធម៌សម្រាប់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទមានលទ្ធផលល្អជាងមុន។”*

មន្ត្រីតុលាការក្នុងខេត្តបាត់ដំបង តំបន់គោលដៅអនុវត្តគម្រោងរបស់អង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ។

*“កាលពីមុនខ្ញុំមិនយល់អ្វីទៅដែលហៅថា អំពើហិង្សាទាក់ទងនឹងយេនឌ័រនោះទេ ខ្ញុំបានត្រឹមតែព្យាបាលអ្នកជំងឺដែលមានរបួសស្នាមតែប៉ុណ្ណោះ ប៉ុន្តែឥឡូវនេះខ្ញុំបានយល់ដឹងបន្ថែមពីស្ថានភាពរបស់ស្ត្រីរងគ្រោះ និងអាចផ្តល់សេវាថែទាំបានច្រើនជាងមុន។”*

មន្ត្រីឆ្មបនៅមន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង តំបន់គោលដៅអនុវត្តគម្រោងរបស់អង្គការឃែរកម្ពុជា។

# ករណីសិក្សា

អ្នកបម្រើការនៅហាងខារ៉ាអូខេមួយកន្លែងក្នុងរាជធានីភ្នំពេញ។

រំដួល មានអាយុ២៤ឆ្នាំ នាងជាអ្នកមកពីខេត្តព្រៃវែង ស្ថិតក្នុងគ្រួសារដែលមានបងប្អូនប្រុស និងស្រី ចំនួន ៧នាក់។ ដើម្បីជួយជីវភាពក្រុមគ្រួសារ នាងបានផ្លាស់មកភ្នំពេញស្វែងរកការងារធ្វើដើម្បីបានប្រាក់ផ្ញើទៅផ្ទះ។ នាងបានបម្រើការងារនៅហាងខារ៉ាអូខេរយៈពេល៤ឆ្នាំ ខណៈដែលនាងកំពុងបម្រើការងារ បានធ្វើជាសាក្សីទាក់ទងនឹងករណីអំពើហិង្សាដោយពាក្យសំដី និងលើផ្លូវកាយដែលបានកើតឡើងលើមិត្តភក្តិរបស់នាងហើយរូបនាងផ្ទាល់ក៏ធ្លាប់ជួបប្រទះអំពើហិង្សានេះដែរ ពេលខ្លះរហូតដល់មានរបួសស្នាមទៀតផង។ នាងធ្លាប់ត្រូវបានអតិថិជនជេរប្រមាថនៅពេលដែលនាងចាប់ផ្តើមធ្វើការងារដំបូងហើយនាងក៏មិនដឹងថាធ្វើដូចម្តេចនោះដែរ ថែមទាំងមិនដឹងថាទៅរកជំនួយនៅទីណា។

រំដួលបានចូលរួមក្នុងព្រឹត្តិការណ៍ផ្សព្វផ្សាយពីចំណេះដឹងអំពីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័ររបស់អង្គការ អាក់តិដ (ACTED)។ ខ្ញុំទើបតែបានដឹងថា ករណីអំពើហិង្សាដែលបានកើតឡើងចំពោះមិត្តរបស់ខ្ញុំ និងខ្ញុំកាលពីពេលមុនជាករណីអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ខ្ញុំបានត្រឹមតែអត់ទ្រាំនឹងអំពើហិង្សានោះ ហើយចាត់ទុកវាជាវាសនាអាក្រក់របស់ខ្ញុំតែប៉ុណ្ណោះ។ តាមរយៈការចូលរួមផ្សព្វផ្សាយរបស់អង្គការអាក់តិដ ខ្ញុំបានធ្វើការប្រៀបធៀបនូវអ្វីដែលបានរៀនសូត្រជាមួយអ្វីដែលបានកើតឡើងលើរូបខ្ញុំ ទើបដឹងថាខ្ញុំត្រូវបានគេរំលោភបំពានសិទ្ធិរបស់ខ្ញុំ។ បច្ចុប្បន្ន ខ្ញុំដឹងពីរបៀបទប់ទល់នឹងស្ថានភាពបែបនោះ ប្រសិនបើគេប្រព្រឹត្តមកលើរូបខ្ញុំសារជាថ្មីម្តងទៀត។

រំដួលបានរៀនសូត្រជាច្រើនពីការអប់រំផ្សព្វផ្សាយដែលបានផ្តល់ដោយអង្គការអាក់តិដ។ នាងបានយល់ដឹងអំពីរបៀបនៃការស្វែងរកសេវានៅពេលដែលនាងត្រូវការវា។ ឥឡូវនេះខ្ញុំមានជំនឿចិត្ត និងអាចដោះស្រាយបញ្ហាជាមួយអតិថិជនដែលប្រព្រឹត្តមិនត្រឹមត្រូវមកលើរូបខ្ញុំ។ ឧទាហរណ៍៖ នៅថ្ងៃមួយ អតិថិជនបានព្យាយាមបង្ខំខ្ញុំឱ្យចេញក្រៅ និងទៅគេងជាមួយគាត់។ ពេលនោះខ្ញុំបានបដិសេធន៍ និងធ្វើឱ្យគាត់ខឹងយ៉ាងខ្លាំង។ គាត់បានបង្ខំសួរខ្ញុំថា តើខ្ញុំត្រូវការប្រាក់ប៉ុន្មាន ហើយខ្ញុំបានឆ្លើយតបទៅគាត់វិញថា ថ្វីត្បិតតែខ្ញុំជាអ្នកបម្រើសេវាកំសាន្ត ប៉ុន្តែខ្ញុំទទួលបានសិទ្ធិការពារពីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយអ្វីដែលគាត់កំពុងប្រព្រឹត្តមកលើខ្ញុំគឺកំពុងរំលោភសិទ្ធិរបស់ខ្ញុំ ម្យ៉ាងទៀតគឺផ្ទុយនឹងច្បាប់ បន្ទាប់មកគាត់ក៏ចាកចេញទៅ។ គាត់ខឹងខ្លាំងណាស់ ប៉ុន្តែខ្ញុំអាចបន្តធ្វើការងាររបស់ខ្ញុំដោយគ្មានការភ័យខ្លាច។ នាងមានការជឿជាក់ថា ប្រសិនបើអតិថិជនម្នាក់នោះនៅតែបន្តរំខាននាងទៀត នាងនឹងរាយការណ៍ទៅប្រធានរបស់នាង ហើយស្វែងរកជំនួយតាមរយៈការទូរស័ព្ទទៅមន្ត្រីនគរបាល។

> *“កាលពីមុន ខ្ញុំបានត្រឹមតែអត់ទ្រាំនឹងអំពើហិង្សា ហើយចាត់ទុកវាជាវាសនាអាក្រក់របស់ខ្ញុំតែប៉ុណ្ណោះ។ បច្ចុប្បន្នខ្ញុំដឹងពីរបៀបទប់ទល់នឹងស្ថានភាពបែបនោះប្រសិនបើគេប្រព្រឹត្តមកលើរូបខ្ញុំសារជាថ្មីម្តងទៀត។”*




ការបណ្តុះបណ្តាលមិត្តអប់រំមិត្ត កម្មវិធី ACTED ភ្នំពេញ

**ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា**

១៦B ផ្លូវរដ្ឋសភា ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ៖ +៨៥៥ (០) ២៣ ២១៣ ៤៧០
ទូរសារលេខ៖ ៨៥៥ (០) ២៣ ២១៣ ៤១៣

**ក្រសួងកិច្ចការនារី**

ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារលេខ៖ +៨៥៥ (០) ២៣ ៨៨០ ៧៣៧
Email:mwa@online.com.kh, www.mowa.gov.kh
www.facebook.com/mowa.gov.kh